របាយការណ៍វាយតម្លៃលទ្ធភាពសង
លេខ: ០០៤/២៤
ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២៤

# ធនាគារ អេស៊ីលីដា ភីអិលស៊ី

| ចំណាត់ថ្នាក់ឥណទាន | | ព័ត៌មានសញ្ញាបណ្ណ | |
|---|---|---|---|
| ចំណាត់ថ្នាក់ឥណទានក្រុមហ៊ុន | **KhAA** | ទំហំ | ១០០ លានដុល្លារអាមេរិក |
| ទស្សនវិស័យ | **ស្ថិរភាព** | ចំនួននៃការទូទាត់ | ឆ្នាំទី១ និងទី២ ទូទាត់ការប្រាក់<br>ឆ្នាំទី៣ ដល់ ឆ្នាំទី៧ រំលស់ប្រចាំឆ្នាំ |
| ចំណាត់ថ្នាក់ឥណទានសញ្ញាបណ្ណ | **khAA** | រយៈពេលឥណប្រតិទាន | ៧ឆ្នាំ |
| | | ប្រភេទ | បន្ទាប់បន្សំ មិនមានទ្រព្យតម្កល់ |
| | | អត្រាគូប៉ុង | ៨,៥% ក្នុង១ឆ្នាំ |


**អ្នកវាយតម្លៃ៖**

លោក ស៊ីសុវត្ថិ ចក្រការា CFA
s.chakara@ratingagencyofcambodia.com.kh
(+៨៥៥) ១៧ ៣៩៨ ៧៧៧

កញ្ញា សៀង ដារីយ៉ា
s.darya@ratingagencyofcambodia.com.kh
(+៨៥៥) ១៧ ៣៨៦ ៧៧៧

កញ្ញា ពៅ ស៊ុនវណ្ណដែត
p.sunvandeth@ratingagencyofcambodia.com.kh
(+៨៥៥) ១៧ ៣១៨ ៧៧៧

កញ្ញា លឹម អច្ឆរាទេពី
l.achhakratepy@ratingagencyofcambodia.com.kh
(+៨៥៥) ១៧ ២៥០ ៧៧៧

លោក ពេជ្រ ម៉េងហ៊ុយ
p.menghuy@ratingagencyofcambodia.com.kh
(+៨៥៥) ១៧ ៩៩៣ ៣៣៧


## ហេតុផលសំខាន់ៗនៅក្រោយការវាយតម្លៃ

យើងផ្តើមការវាយតម្លៃលទ្ធភាពសងរបស់ ធនាគារ អេស៊ីលីដា ភីអិលស៊ី («ACLEDA» ឬ «ក្រុមហ៊ុន») ដោយការផ្តល់ចំណាត់ថ្នាក់ឥណទានក្រុមហ៊ុន (ICR) គឺ «**khAA**» (ចំណាត់ថ្នាក់ជាតិ) ដែលនៅក្នុងបរិបទកម្ពុជាបង្ហាញនូវ «*សមត្ថភាពខ្លាំងក្នុងការបំពេញកាតព្វកិច្ចផ្នែកហិរញ្ញវត្ថុ*»។

ការវាយតម្លៃចំណាត់ថ្នាក់ឥណទានក្រុមហ៊ុនផ្សំដោយសមាសភាគពីរ៖ ទម្រង់ឥណទានឯករាជ្យ (SACP) និងកត្តាគាំទ្រខាងក្រៅ (ESF)។ SACP វិភាគទម្រង់ឥណទានតាមរយៈហានិភ័យអាជីវកម្ម និងហានិភ័យហិរញ្ញវត្ថុរបស់ ACLEDA ។ ទម្រង់ឥណទានឯករាជ្យ (SACP) របស់ ACLEDA ចំណាត់ថ្នាក់ «**khA**» បង្ហាញពីទម្រង់ «ហានិភ័យទាប»។

កត្តាគាំទ្រខាងក្រៅអាចបង្កើតបានដោយភាគីពាក់ព័ន្ធដូចជា ក្រុមហ៊ុនមេ ឬ ក្រុមហ៊ុនហូលឌីង (Group Support) ឬដោយអង្គភាពពាក់ព័ន្ធរបស់រាជរដ្ឋាភិបាល (Country Support)។ ក្នុងករណី ACLEDA កត្តា-គាំទ្រខាងក្រៅគឺ «ខ្លាំង» ដែលមានការគាំទ្រដោយអង្គភាពពាក់ព័ន្ធរបស់រាជរដ្ឋាភិបាល ។ ដូច្នេះ ICR ត្រូវបានកើនឡើងមួយកម្រិត គឺ «**khAA**»។

ពិន្ទុស្តារឡើងវិញ(RS) «ហានិភ័យទាបណាស់» មានន័យថា ម្ចាស់បំណុលអាចសង្ឃឹម អត្រាស្តារឡើងវិញ គឺ១០០% ទោះបីជាមូលបត្រនេះ មានលក្ខណៈបន្ទាប់បន្សំ និងមិនមានទ្រព្យតម្កល់ក៏ដោយ។ នៅក្នុងលក្ខខណ្ឌនេះ ចំណាត់ថ្នាក់ឥណទានសញ្ញាបណ្ណ គឺ «**khAA**» (ចំណាត់ថ្នាក់ជាតិ) ស្មើនឹង ចំណាត់ថ្នាក់ឥណទានក្រុមហ៊ុន។

ACLEDA គឺជា ធនាគារពាណិជ្ជឈានមុខគេនៅកម្ពុជា ជាមួយនឹងបណ្តាញប្រតិបត្តិការយ៉ាងធំទូលាយគ្រប-ដណ្តប់ទូទាំង ២៥ខេត្ត និងរាជធានី ក្នុងព្រះរាជាណាចក្រកម្ពុជា។ យើងកត់សម្គាល់ថា យុទ្ធសាស្ត្រអភិរក្ស ជាមួយនឹង កំណើនឥណទានទាបជាងមធ្យម ឥណទានមានបញ្ហាស្ថិតក្នុងកម្រិតគ្រប់គ្រងបាន និងការធ្វើពិពិធកម្មហានិភ័យ ជៀសឆ្ងាយពីការប្រថុយប្រថាន ឬវដ្តនៃសេដ្ឋកិច្ច។


©រក្សាសិទ្ធគ្រប់យ៉ាងដោយក្រុមហ៊ុនរេតធីង អេជេនស៊ី អហ្វ (ខេមបូឌា) ម.ក ឆ្នាំ២០២៤
©Copyright 2024, RATING AGENCY OF (CAMBODIA) PLC. All rights reserved.


អាសយដ្ឋាន៖ អគារលេខ២៤៦,មហាវិថីព្រះមុនីវង្ស ភូមិ១០ សង្កាត់បឹងរាំង ខណ្ឌដូនពេញ រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា
Address: #246, Preah Monivong Blvd, Village 10, Sangkat Boeung Raing, Khan Daun Penh, Phnom Penh, Kingdom of Cambodia
ទូរសព្ទ៖ (៨៥៥)២៣ ៩០២ ៤០៨ សារអេឡិចត្រូនិច info@ratingagencyofcambodia.com.kh
Phone: (+855)23 902 408 Email: info@ratingagencyofcambodia.com.kh
RAC website

យើងរំពឹងថា មូលបត្របំណុលបន្ទាប់បន្សំនេះ មានលក្ខណសម្បត្តិគ្រប់គ្រាន់ក្នុងការកំណត់ជា ដើមទុនថ្នាក់ទី២ ACLEDA នឹងពង្រឹងបន្ថែមភាពរឹងមាំរបស់ខ្លួន បន្ទាប់ពីការធ្លាក់ចុះក្នុងសេដ្ឋកិច្ចដែលបង្កឡើងដោយ វិបត្តិ Covid-១៩ និងផលប៉ះពាល់អវិជ្ជមាននៃអត្រាការប្រាក់ខ្ពស់។

### ទស្សនវិស័យ

ប្រាក់ចំណូលរបស់ ACLEDA ត្រូវបានជំរុញយ៉ាងខ្លាំងដោយសកម្មភាពសេដ្ឋកិច្ចក្នុងប្រទេសកម្ពុជា។ កំឡុងពេលនេះ សូចនាករ និងការព្យាករភាគច្រើន ចង្អុលបង្ហាញពីការអភិវឌ្ឍវិជ្ជមានចាប់ពីឆ្នាំ ២០២៥ តទៅមុខ។ យើងរំពឹងថា ACLEDA នឹងមើលឃើញពីអត្ថប្រយោជន៍នេះនៅក្នុងផលបត្រឥណទានរបស់ខ្លួន តាមរយៈការធ្វើឱ្យប្រសើរឡើងនូវគុណភាពឥណទាន និងបន្តបង្កើនបរិមាណ ឱ្យស្ថិតនៅក្រោមការគ្រប់គ្រង។ គណៈគ្រប់គ្រងដ៏មានជំនាញរបស់ក្រុមហ៊ុន និងទ្រនាប់ដើមទុនដែលក្រុមហ៊ុនរក្សាបាន ធ្វើឱ្យ ACLEDA មានភាពងាយស្រួលក្នុងការឆ្លើយតបទៅនឹងហានិភ័យដែលអាចកើតមាន។ ដូច្នេះ ក្នុងការយល់ឃើញរបស់យើង ទស្សនវិស័យគឺ «**ស្ថិរភាព**»។

### កត្តាដែលមានឥទ្ធិពលលើបម្រែបម្រួលការវាយតម្លៃ

ករណីដែលអាចប្រសើរឡើង ចំណាត់ថ្នាក់ឥណទានរបស់ ACLEDA គឺមានការរឹតបន្តឹងបន្តិចបន្តួច នៅកម្រិតបន្ទាប់ (khAAA) ដោយសារចំណាត់ថ្នាក់របស់ប្រទេសកម្ពុជា (Sovereign rating of Cambodia)។
ករណីដែលអាចថយចុះ ការខូចខាតនៅក្នុងបរិយាកាសសេដ្ឋកិច្ច ឬ ក្នុងដំណើរប្រតិបត្តិការ អាចធ្វើឱ្យយើងពិចារណាលើការវាយតម្លៃ។

### បញ្ហាដែលត្រូវត្រួតពិនិត្យ

និន្នាការឥណទានមិនដំណើរការ អត្រាកំណើនឥណទាន និងការកាន់កាប់ចំណែកទីផ្សារ នៅក្នុងវិស័យធនាគារ ត្រូវតែមានការតាមដានយ៉ាងជាប់លាប់ ព្រោះអាចបង្ហាញពីការផ្លាស់ប្តូរយុទ្ធសាស្ត្រ ទម្រង់ហានិភ័យ និងសមត្ថភាពប្រកួតប្រជែង។

## សេចក្តីសង្ខេបអំពី ធនាគារ អេស៊ីលីដា ភីអិលស៊ី

### ទិដ្ឋភាពទូទៅ

យុទ្ធសាស្ត្ររបស់ ACLEDA បាននាំមកនូវស្ថិរភាព និងមិនផ្លាស់ប្តូរនៃចំណូលពីការវិនិយោគ ដែលលើសពីធនាគារពាណិជ្ជជាមធ្យម ក្នុងរយៈពេល ១៤ឆ្នាំកន្លងមកនេះ។ ការប្រតិបត្តិនេះសម្រេចបាន នៅខណៈពេលដែលមានការប្រុងប្រយ័ត្នខ្ពស់ ប៉ុន្តែកំណើនឥណទាន ជាក់លាក់ រក្សាបានយ៉ាងច្រើនពាក់ព័ន្ធនឹងបទប្បញ្ញត្តិទ្រនាប់ដើមទុន លើសពីតម្រូវការដែលបានចែងក្នុងច្បាប់ និងរក្សាបានយ៉ាងត្រឹមត្រូវចំពោះគោលជំហររបស់ធនាគារដែលជា «ប្រជាធនាគារដែលលោកអ្នកជឿទុកចិត្ត»។

ការធ្វើពិពិធកម្មតាម វិស័យ លក្ខខណ្ឌភូមិសាស្ត្រ រួមបញ្ចូលគ្នាជាមួយនឹងការយល់ដឹងយ៉ាងស៊ីជម្រៅពីអតិថិជនរបស់ខ្លួន គឺជាមូលដ្ឋានដែលទទួលបានតាមរយៈប្រវត្តិសាស្ត្រដ៏យូរអង្វែងរបស់ ACLEDA ដែលដំបូង ចាប់ផ្តើមពីអង្គការក្រៅរដ្ឋាភិបាល បន្ទាប់មកជា គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ បានអនុញ្ញាតឱ្យ ACLEDA គ្រប់គ្រងបាននូវឥណទានដែលមានបញ្ហាឱ្យនៅកម្រិតទាប ក្រោមការណែនាំរបស់គណៈគ្រប់គ្រងប្រកបដោយសុចរិតភាព និងការពារចំពោះហានិភ័យដែលអាចកើតមាន។

វិបត្តិសេដ្ឋកិច្ចដែលបង្កឡើងដោយវិបត្តិ Covid-១៩ និងអំឡុងពេលនៃអតិផរណាឡើងខ្ពស់បានជំរុញឱ្យធនាគារជាតិនៃកម្ពុជា បានរឹតបន្តឹងគោលនយោបាយរូបិយវត្ថុចាប់ពីខែមីនា ឆ្នាំ ២០២២។ ភាពតានតឹងនៃភូមិសាស្ត្រនយោបាយ និងជម្លោះ បានបន្ថែមការធ្លាក់ចុះទៅក្នុងសេដ្ឋកិច្ចសកល។ មិនមែនជារឿងគួរឱ្យភ្ញាក់ផ្អើលទេ ដែលប្រទេសកម្ពុជាទទួលរងផលប៉ះពាល់នេះ ដោយសារតែការប៉ះទង្គិចនេះទាក់ទងទៅនឹងការនាំចេញ និងវិស័យទេសចរណ៍។ កត្តាចម្បងទាំងនេះ បានធ្វើឱ្យ ACLEDA មានការបារម្ភយ៉ាងខ្លាំងនៅឆ្នាំ ២០២៣ ជាមួយនឹងការកើនឡើងឥណទានដែលមានបញ្ហា កំណើនឥណទានតិចជាងមុន និងប្រាក់ចំណូលធ្លាក់ចុះ។

មូលបត្របន្ទាប់បន្សំ នឹងធ្វើការបោះផ្សាយ គឺត្រូវបានរំពឹងថានឹងមានលក្ខណសម្បត្តិគ្រប់គ្រាន់សមស្របនឹង ដើមទុនថ្នាក់ទី២ ដែលនឹងពង្រឹងភាពរឹងមាំដល់ស្ថានភាពរបស់ក្រុមហ៊ុន។ នៅក្នុងទស្សនៈរបស់យើង ជម្រើសនៃការបោះផ្សាយមូលនិធិបំណុល គឺសមហេតុផលជាង ការបោះផ្សាយមូលបត្រកម្មសិទ្ធិ ឧទាហរណ៍ ការបោះផ្សាយមូលបត្រកម្មសិទ្ធិ អាចនាំឱ្យខូចខាតតម្លៃហ៊ុនក្នុងទីផ្សារភាគហ៊ុនបច្ចុប្បន្ន។

©រក្សាសិទ្ធគ្រប់យ៉ាងដោយក្រុមហ៊ុនរេធីង អេជេនស៊ី អហ្វ (ខេមបូឌា) ម.ក ឆ្នាំ២០២៤
©Copyright 2024, RATING AGENCY OF (CAMBODIA) PLC. All rights reserved.
អាសយដ្ឋាន៖ អគារលេខ២៤៦,មហាវិថីព្រះមុនីវង្ស ភូមិ១០ សង្កាត់បឹងរាំង ខណ្ឌដូនពេញ រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា
Address: #246, Preah Monivong Blvd, Village 10, Sangkat Boeung Raing, Khan Daun Penh, Phnom Penh, Kingdom of Cambodia
ទូរសព្ទ៖ (៨៥៥)២៣ ៩០២ ៤០៨ សារអេឡិចត្រូនិច info@ratingagencyofcambodia.com.kh
Phone: (+855)23 902 408 Email: info@ratingagencyofcambodia.com.kh
RAC website

## ការប្រតិបត្តិ

និន្នាការប្រាក់ចំណូល និងប្រាក់ចំណេញពីប្រតិបត្តិការ មានការកើនឡើងក្នុងអំឡុងឆ្នាំ ២០១០-២០២៤ ប៉ុន្តែប្រាក់ចំណេញក៏មានការធ្លាក់ចុះ នៅឆ្នាំ២០១៧ និងឆ្នាំ ២០២៣ ដែលបណ្តាលមកពី ព្រឹត្តិការណ៍ពិសេស (One-off events) ២០១៧ និងកត្តាម៉ាក្រូសេដ្ឋកិច្ច ២០២៣។ ជាកិត្តិយសដល់គណៈគ្រប់គ្រងរបស់ធនាគារ ACLEDA ដែលបានរក្សាសមត្ថភាពខ្ពស់ចំពោះ លទ្ធភាពសងបំណុល និងផលចំណេញ ទោះបីជាស្ថិតក្នុងលក្ខខណ្ឌមិនអំណោយផលក៏ដោយ។

### របាយការណ៍ហិរញ្ញវត្ថុសង្ខេប

| | ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ ២០២១<br>ដុល្លារអាមេរិក | ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ ២០២២<br>ដុល្លារអាមេរិក | ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ ២០២៣<br>ដុល្លារអាមេរិក | ថ្ងៃទី៣០ ខែកញ្ញា ឆ្នាំ ២០២៤<br>ដុល្លារអាមេរិក |
|---|---|---|---|---|
| **របាយការណ៍ចំណេញ/ខាត** | | | | |
| ចំណូលការប្រាក់សុទ្ធ | ៤០១.៤២៨.៩៤១ | ៤៤៩.៩៣០.៩៩០ | ៤២៦.៦២៩.៦៥១ | ៣៣៣.៨៧២.៨២៧ |
| ចំណូលកម្រៃ និង ជើងសាសុទ្ធ | ៤០.២៧០.៣៥៥ | ៤២.៨៩០.៩៨៦ | ៤២.៧២១.២៦៧ | ២៨.៤៥៩.២៥៧ |
| ចំណេញមុនចំណាយពន្ធលើប្រាក់ចំណេញ | ២០៤.៧៥៣.៤១៧ | ២២៨.៣០៨.១៤៦ | ១៨៤.២៣៧.៥៣០ | ៩២.៣៥០.៤៩១ |
| **ប្រាក់ចំណេញក្នុងការិយបរិច្ឆេទ** | **១៦៦.៦៧៤.៣៤៨** | **១៨១.៨១៤.៧៧៥** | **១៤៨.០១៨.៤២៥** | **៧៣.៦៤០.៩១៥** |
| **របាយការណ៍ស្ថានភាពហិរញ្ញវត្ថុ** | | | | |
| **ទ្រព្យសកម្មសរុប** | **៧.៨៥៥.២៥២.៣២៤** | **៩.០៣១.១៦៣.៣០៦** | **៩.៧៤៤.០៤០.៤៨៦** | **១០.៥៥២.០៦០.៤៥៥** |
| បំណុលសរុប | ៦.៦៥០.២១៧.២៨២ | ៧.៧១៤.៥១៥.៤៨៦ | ៨.៣៦២.០១៩.៦៨៤ | ៩.១១៦.៣១៦.៨៧៩ |
| មូលធនសរុប | ១.២០៥.០៣៥.០៤២ | ១.៣១៦.៦៤៧.៨២០ | ១.៣៨២.០២០.៨០២ | ១.៤៣៥.៧៤៣.៥៧៦ |
| **បំណុលនិងមូលធនសរុប** | **៧.៨៥៥.២៥២.៣២៤** | **៩.០៣១.១៦៣.៣០៦** | **៩.៧៤៤.០៤០.៤៨៦** | **១០.៥៥២.០៦០.៤៥៥** |
| **របាយការណ៍លំហូរសាច់ប្រាក់** | | | | |
| សាច់ប្រាក់សុទ្ធពីសកម្មភាពប្រតិបត្តិការ | ៣៧៣.៩៨០.១៨២ | (១០០.៤៦៤.៩៥៨) | ៧៧៤.៥២៦.៣៧០ | ៨៤១.៧២៥.៧១៦ |
| សាច់ប្រាក់សុទ្ធពីសកម្មភាពវិនិយោគ | (៣៤.៦១៨.៥០៧) | (១៤៥.៨៨៥.៦១៨) | ២៧.៦២២.១១៦ | (៥៦.៩៧៧.០៧២) |
| សាច់ប្រាក់សុទ្ធបានប្រើក្នុងសកម្មភាពហិរញ្ញប្បទាន | (៣៣.២២៧.៨៨២) | ១៩១.៥៥៤.៩៤៨ | (២៧០.៨៧៣.៥៨២) | (២៣៥.៣៧៤.៦២៤) |
| **ការកើនឡើង/ថយចុះ សាច់ប្រាក់និងសាច់ប្រាក់សមមូលសុទ្ធ** | **៣០៦.១៣៣.៧៩៣** | **(៥៤.៧៩៥ .៦២៨)** | **៥៣១.២៧៤.៩០៤** | **៥៤៩.៣៧៤.០២០** |

©រក្សាសិទ្ធគ្រប់យ៉ាងដោយក្រុមហ៊ុនរេតធីង អេជេនស៊ី អហ្វ (ខេមបូឌា) ម.ក ឆ្នាំ២០២៤
©Copyright 2024, RATING AGENCY OF (CAMBODIA) PLC. All rights reserved.
អាសយដ្ឋាន៖ អគារលេខ២៤៦,មហាវិថីព្រះមុនីវង្ស ភូមិ១០ សង្កាត់បឹងរាំង ខណ្ឌដូនពេញ រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា
Address: #246, Preah Monivong Blvd, Village 10, Sangkat Boeung Raing, Khan Daun Penh, Phnom Penh, Kingdom of Cambodia
ទូរសព្ទ៖ (៨៥៥)២៣ ៩០២ ៤០៨ សារអេឡិចត្រូនិច info@ratingagencyofcambodia.com.kh
Phone: (+855)23 902 408 Email: info@ratingagencyofcambodia.com.kh

RAC website

## និយមន័យចំណាត់ថ្នាក់ឥណទាន

| ចំណាត់ថ្នាក់វាយតម្លៃឥណទាន(ចំណាត់ថ្នាក់ជាតិ) | | | |
|---|---|---|---|
| **ចំណាត់ថ្នាក់ជាតិ** | **និយមន័យ** | | |
| khAAA | សមត្ថភាពខ្លាំងណាស់ក្នុងការបំពេញកាតព្វកិច្ចផ្នែកហិរញ្ញវត្ថុ | ១ | ហានិភ័យទាបណាស់ |
| khAA | សមត្ថភាពខ្លាំងក្នុងការបំពេញកាតព្វកិច្ចផ្នែកហិរញ្ញវត្ថុ | ២ | |
| | | | |
| khA | សមត្ថភាពខ្លាំងក្នុងការបំពេញកាតព្វកិច្ចផ្នែកហិរញ្ញវត្ថុ ប៉ុន្តែពេលខ្លះអាចងាយទទួលរងការផ្លាស់ប្តូរអវិជ្ជមានក្នុងកាលៈទេសៈ និងបរិយាកាសសេដ្ឋកិច្ច | ៣ | ហានិភ័យទាប |
| khBBB | សមត្ថភាពគ្រប់គ្រាន់ក្នុងការបំពេញកាតព្វកិច្ចផ្នែកហិរញ្ញវត្ថុ ប៉ុន្តែមានភាពងាយនឹងទទួលរងការផ្លាស់ប្តូរអវិជ្ជមានក្នុង<br>កាលៈទេសៈ និងបរិយាកាសសេដ្ឋកិច្ច | ៤ | |
| khBB | សមត្ថភាពគ្រប់គ្រាន់ក្នុងការបំពេញកាតព្វកិច្ចផ្នែកហិរញ្ញវត្ថុ ប៉ុន្តែងាយរងគ្រោះជាងទៅតាមការផ្លាស់ប្តូរអវិជ្ជមាននៅក្នុង<br>កាលៈទេសៈ និងបរិយាកាសសេដ្ឋកិច្ច | ៥ | ហានិភ័យមធ្យម |
| khB | សមត្ថភាពគ្រប់គ្រាន់ក្នុងការបំពេញកាតព្វកិច្ចផ្នែកហិរញ្ញវត្ថុ ប៉ុន្តែទំនងជារងផលប៉ះពាល់ដោយការផ្លាស់ប្តូរអវិជ្ជមាននៅក្នុង<br>កាលៈទេសៈ និងបរិយាកាសសេដ្ឋកិច្ច | ៦ | |
| khCCC | សមត្ថភាពបំពេញកាតព្វកិច្ចផ្នែកហិរញ្ញវត្ថុ អាស្រ័យលើលក្ខខណ្ឌអាជីវកម្ម ហិរញ្ញវត្ថុ និងសេដ្ឋកិច្ចអំណោយផល | ៧ | ហានិភ័យខ្ពស់ |
| khCC | សមត្ថភាពខ្សោយក្នុងការបំពេញកាតព្វកិច្ចផ្នែកហិរញ្ញវត្ថុ | ៨ | |
| khC | ទំនងជាមិនអាចបំពេញកាតព្វកិច្ចផ្នែកហិរញ្ញវត្ថុ | ៩ | ហានិភ័យខ្ពស់ណាស់ |
| khD | មិនអាចបំពេញកាតព្វកិច្ចផ្នែកហិរញ្ញវត្ថុ មួយផ្នែក ឬ ទាំងអស់ | ១០ | |

**សេចក្តីថ្លែងមិនទទួលខុសត្រូវ**

ព័ត៌មាន និងទិន្នន័យស្ថិតិនៅទីនេះត្រូវបានទទួលពីប្រភពដែលយើងជឿថាអាចទុកចិត្តបាន។ ព័ត៌មានបែបនេះមិនត្រូវបានផ្ទៀងផ្ទាត់ដោយឯករាជ្យទេ ហើយយើងមិនតំណាង ឬការធានាចំពោះភាពត្រឹមត្រូវច្បាស់លាស់ និងភាពពេញលេញរបស់ព័ត៌មានឡើយ។ រាល់មតិ ឬការប៉ាន់ប្រមាណនៅទីនេះឆ្លុះបញ្ចាំងពីការវិនិច្ឆ័យរបស់ក្រុមហ៊ុន រេតធីង អេជេនស៊ី អហ្វ (ខេមបូឌា)ម.ក (ដែលហៅកាត់ថា "RAC") នៅកាលបរិច្ឆេទនៃរបាយការណ៍នេះ ហើយអាចផ្លាស់ប្តូរបានគ្រប់ពេលដោយមិនមានការជូនដំណឹងជាមុន។ រាល់ការដាក់ពិន្ទុ មតិ ការប៉ាន់ប្រមាណ ការព្យាករណ៍ ឬការវាយតម្លៃហានិភ័យនៅទីនេះ បង្កើតជាការវិនិច្ឆ័យគិតត្រឹមកាលបរិច្ឆេទនៃរបាយការណ៍នេះ ហើយមិនអាចមានការធានាថា លទ្ធផល ឬព្រឹត្តិការណ៍នាពេលអនាគតនឹងមានភាពស៊ីសង្វាក់គ្នាជាមួយនឹងការដាក់ពិន្ទុ មតិ ការប៉ាន់ប្រមាណ ការព្យាករណ៍ ឬការវាយតម្លៃហានិភ័យណាមួយឡើយ។ ព័ត៌មាននៅក្នុងឯកសារនេះគឺអាចផ្លាស់ប្តូរដោយគ្មានការជូនដំណឹង ភាពត្រឹមត្រូវច្បាស់លាស់របស់វាមិនត្រូវបានធានាទេ វាអាចមិនពេញលេញ ឬបង្រួម ហើយវាប្រហែលជាមិនមែនព័ត៌មានធំ ទាំងអស់ទាក់ទងនឹងក្រុមហ៊ុន (ឬក្រុមហ៊ុនច្រើន) ដែលយោងទៅតាមរបាយការណ៍នេះទេ ហើយ RAC មិនស្ថិតនៅក្រោមកាតព្វកិច្ច ធ្វើបច្ចុប្បន្នភាពព័ត៌មាននៅក្នុងរបាយការណ៍នេះផងដែរ។ ក្នុងវិសាលភាពដែលបានអនុញ្ញាតដោយច្បាប់ RAC និងនាយក បុគ្គលិក ភ្នាក់ងារ និងអ្នកតំណាងរបស់ខ្លួនមិនទទួលខុសត្រូវចំពោះការខូចខាត ដោយផ្ទាល់ ឬសំណងណាមួយចំពោះបុគ្គល ឬអង្គភាពណាមួយ រាប់បញ្ចូលទាំង ប៉ុន្តែមិនកំណត់ដោយការធ្វេសប្រហែសណាមួយនៅក្នុងផ្នែកនៃ ឬបញ្ហាអាសន្នណាមួយនៅក្នុង ឬលើសពីការគ្រប់គ្រងរបស់ RAC ឬនាយក បុគ្គលិក ភ្នាក់ងារ និងអ្នកតំណាងណាមួយរបស់ខ្លួន ដែលកើតឡើងពី ឬពាក់ព័ន្ធនឹងព័ត៌មានដែលមាននៅទីនេះ ឬ ការប្រើប្រាស់ ឬអសមត្ថភាពក្នុងការប្រើប្រាស់ព័ត៌មានបែបនេះ។

©រក្សាសិទ្ធគ្រប់យ៉ាងដោយក្រុមហ៊ុនរេតធីង អេជេនស៊ី អហ្វ (ខេមបូឌា) ម.ក ឆ្នាំ២០២៤
©Copyright 2024, RATING AGENCY OF (CAMBODIA) PLC. All rights reserved.

អាសយដ្ឋាន៖ អគារលេខ២៤៦,មហាវិថីព្រះមុនីវង្ស ភូមិ១០ សង្កាត់បឹងរាំង ខណ្ឌដូនពេញ រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា
Address: #246, Preah Monivong Blvd, Village 10, Sangkat Boeung Raing, Khan Daun Penh, Phnom Penh, Kingdom of Cambodia
ទូរសព្ទ៖ (៨៥៥)២៣ ៩០២ ៤០៨ សារអេឡិចត្រូនិច info@ratingagencyofcambodia.com.kh
Phone: (+855)23 902 408 Email: info@ratingagencyofcambodia.com.kh

RAC website